**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: ..១៦១/២០២៣.............អអរ**

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តត្បូងឃ្មុំ"

នាព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តត្បូងឃ្មុំ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តត្បូងឃ្មុំ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តត្បូងឃ្មុំ ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

### I. ស្ថានភាពទូទៅ

ខេត្តត្បូងឃ្មុំ បែងចែកចេញជា ៧ក្រុង-ស្រុក ៦៤ឃុំ-សង្កាត់ និង៨៧៥ភូមិ ដែលមានប្រជាពលរដ្ឋរស់នៅសរុបចំនួន ៨៧៤.៩៥៣នាក់ ស្មើនឹង១៩៩.១១៣គ្រួសារ ក្នុងនោះ ប្រជាពលរដ្ឋប្រកបមុខរបរកសិកម្ម៨៥% ពាណិជ្ជកម្ម១៤% និងមុខរបរផ្សេងៗ ១%។ ខេត្តមានទំហំសេដ្ឋកិច្ចប្រមាណ ១.៣៤១លានដុល្លារអាមេរិក ស្មើនឹង ២,៨% នៃសេដ្ឋកិច្ចជាតិ ដោយចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់មានចំនួន ១.៤៥២ដុល្លារអាមេរិក។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ដោយបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះចំនួន ៤១.២២១គ្រួសារ ចំណាយទឹកប្រាក់សរុបចំនួន ២២៥.២១៤.១៨១.០០០រៀល, ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ចំណាយថវិកាចំនួន ៤.៥០៦.១៦០.០០០រៀល, ឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យដោយសារសម្ពាធអតិផរណា ១១.៨៣៤គ្រួសារ ចំណាយថវិកា ១.៥៧៦.៣៤២.២០០រៀល និងទឹកជំនន់ ចំនួន ៣.២០៨គ្រួសារ ចំណាយថវិកា ១.៤៤៥.០៤០.០០០រៀល។
- **វិស័យកសិកម្ម៖** ផ្ទៃដីទូទាំងខេត្ត មានលក្ខណៈអំណោយផលដល់ដំណាំកសិកម្ម និងកសិឧស្សាហកម្មជាច្រើនមុខ ដោយក្នុងនោះ ដំណាំអាទិភាពក្នុងខេត្តរួមមាន ដំណាំស្រូវអនុវត្តលើផ្ទៃដី ៨៨.៣៨០ហិកតា សម្រេចបានបរិមាណផល ៣១៥.៣១៤តោន, កៅស៊ូ ៨៥.៨៦៩ហិកតា បរិមាណផល ៨០.៩៧៥តោន ក្រៅពីនោះមានដំណាំម្រេច ដំឡូងមី ស្វាយចន្ទី ស្វាយ ពោត និងដំណាំរួមផ្សំមួយចំនួនទៀត ដែលចូលរួមលើកស្ទួយផលិតកម្មកសិកម្ម ក៏ដូចជាជីវភាពប្រជាពលរដ្ឋទូទាំងខេត្តផងដែរ។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ និងការផ្តល់សេវាសាធារណៈ៖** ដោយមានការសហការគ្នារវាងគណៈបញ្ជាការឯកភាពខេត្ត អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទាំងអស់ ទូទាំងខេត្តរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់បានយ៉ាងល្អប្រសើរ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពទាំង ៧ចំណុច ទទួលបានលទ្ធផលគួរកត់សម្គាល់ បទល្មើសគ្រប់ប្រភេទ ល្បែងស៊ីសង គ្រឿងញៀនជាអាទិ៍ ត្រូវបានបង្ក្រាប និងកាត់បន្ថយជាបន្តបន្ទាប់។ ជាមួយគ្នានេះ ក្រៅពីការថែរក្សាសុខសុវត្ថិភាពជូនប្រជាប្រជាពលរដ្ឋ រដ្ឋបាលខេត្តក៏បាន យកចិត្តទុកដាក់ក្នុងការពង្រឹងការផ្តល់សេវាសាធារណៈ តាមរយៈយន្តការច្រកចេញ-ចូលតែមួយ ក្នុងន័យបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរ។ យន្តការនេះ បានផ្តល់សេវាជូនប្រជាពលរដ្ឋសរុប ៦២.៧៨៦សេវា ទទួលបានចំណូល ៧.១៩៤.៨៤២.៥៥៧រៀល។
- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៖** រដ្ឋបាលខេត្ត បានស្ថាបនា និងថែទាំជាប្រចាំទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ទាំងក្នុងទីរួមខេត្ត ទីជនបទ និងការកែលម្អសោភណ្ឌភាពទីក្រុង ទាំងការសាងសង់ស្ថានីយ៍ផលិតទឹកស្អាត អាងប្រព្រឹត្តកម្មទឹកកខ្វក់ ប្រព័ន្ធលូរំដោះទឹកសម្រេចបានជាបន្តបន្ទាប់ លើសពីនេះ អ្វីដែលជាសមិទ្ធផលយ៉ាងធំធេងនោះគឺ ស្ពានស្ទឹងត្រង់-ក្រូចឆ្មា ដែលបានផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ រដ្ឋបាលខេត្តបានធ្វើ

ការតភ្ជាប់បណ្ដាញអគ្គិសនីគ្រប់ភូមិទាំងអស់ និងបណ្ដាញទឹកស្អាតនៅទីប្រជុំជនក៏ត្រូវបានតភ្ជាប់ស្ទើតែ១០០% ផងដែរ។

- **វិស័យទេសចរណ៍៖** រដ្ឋបាលខេត្ត បានខិតខំកែលម្អខេត្ត ឱ្យទៅជាខេត្តទេសចរណ៍មួយ ក្នុងន័យលើកកម្ពស់ជីវភាពប្រជាពលរដ្ឋបន្ថែម តាមរយៈវិស័យទេសចរណ៍នេះ។ បច្ចុប្បន្ននេះ ខេត្តមានរមណីយដ្ឋានធម្មជាតិ២កន្លែង និងកែច្នៃ ៦កន្លែង តំបន់ទឹកធ្លាក់ ចម្ការធុរេន ចម្ការកៅស៊ូជាដើម។ លើសពីនេះ ទន្លេសិប្បនិម្មិត មិនត្រឹមតែអាចទាក់ទាញភ្ញៀវទេសចរទៅទស្សនា ថែមទាំងជាប្រភពទឹកសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ផងដែរ។
- **ការអភិវឌ្ឍធនធានមនុស្ស៖** រដ្ឋបាលខេត្ត បានខិតខំកសាង និងពង្រីកសាលារៀនបន្ថែម ឱ្យបានទៅដល់ទីជនបទ សំដៅជំរុញឱ្យកុមារទាំងអស់ទទួលបានការអប់រំគ្រប់ៗគ្នា។ ខេត្តមានមត្តេយ្យសិក្សាចំនួន២៣៣, បឋមសិក្សា ៤០៦, អនុវិទ្យាល័យ៥២, វិទ្យាល័យ ២៨, សាកលវិទ្យាល័យចំនួន១ ដោយក្នុងឆ្នាំសិក្សា២០២១-២០២២ ខេត្តមានសិស្សនិទ្ទេសA ចំនួន២៩នាក់ ក្នុងនោះស្រី ២១នាក់។ ជាមួយគ្នានេះ ខេត្តក៏បានរៀបចំឱ្យមានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈដើម្បីអប់រំជំនាញពិត វិជ្ជាជីវៈដល់ប្រជាពលរដ្ឋផងដែរ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានប្ដេជ្ញាខិតខំបន្តអនុវត្តនូវគោលនយោបាយយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំដៅរួមចំណែកក្នុងការរក្សាបាននូវសន្តិសុខ ស្ថិរភាពនយោបាយ សង្គម ជំរុញនូវការអភិវឌ្ឍលើគ្រប់វិស័យ ពិសេសការលើកកម្ពស់ការងារកសិកម្ម ប្រែក្លាយទៅជាខេត្តស៊ីវិល័យ (Smart Area) និងការជំរុញការអនុវត្តយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ជាមួយគ្នានេះ រដ្ឋបាលខេត្តបានត្រៀមខ្លួនរួចជាស្រេច ក្នុងការថែរក្សា ការពារសន្តិសុខ សណ្ដាប់ធ្នាប់ ស្ថិរភាពនយោបាយ និងសុវត្ថិភាពសង្គម ក្នុងពេលកម្ពុជា ធ្វើជាម្ចាស់ផ្ទះក្នុងព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នាពេលខាងមុខនេះ៕

ថ្ងៃព្រហស្បតិ៍ ១កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣